# អ.វ.ត.ក - សំណុំរឿង ០០២
# សវនាការលើអង្គសេចក្តី ដំណាក់កាលទី១

ខែមីនា ឆ្នាំ២០១២

ការជំនុំជម្រះក្តីអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបីរូប គឺ នួន ជា អៀង សារី និង ខៀវ សំផន ក្នុងសំណុំរឿង ០០២ បានចាប់ផ្តើមដំណើរការតាំងពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។ ជនជាប់ចោទទាំងបីរូបត្រូវបានចោទប្រកាន់ពីបទ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង អំពើប្រល័យពូជសាសន៍។

អង្គជំនុំជម្រះសាលាដំបូងបានបំបែកដំណើរការនីតិវិធីក្នុងសំណុំរឿងទៅជាដំណាក់កាលតូចៗ ដែលដំណាក់កាលនីមួយៗពិភាក្សាលើផ្នែកខុសៗគ្នានៃដីកាដំណោះស្រាយ។ សវនាការដំណាក់កាលទី១ផ្តោតការពិភាក្សាទៅលើការជម្លៀសប្រជាជនដំណាក់កាលទី១និងទី២ (លើកទី១ជម្លៀសចេញពីទីក្រុងភ្នំពេញនៅឆ្នាំ ១៩៧៥ និងលើកទី២ ជម្លៀសពីទីប្រជុំជនទៅជនបទ ក្នុងអំឡុងឆ្នាំ ១៩៧៥ - ១៩៧៧)។ ក្នុងដំណាក់កាលនេះដែរ អង្គជំនុំជម្រះក៏នឹងពិភាក្សាលើតួនាទីរបស់ជនជាប់ចោទពាក់ព័ន្ធនឹងការបង្កើតគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ ដែលពាក់ព័ន្ធនឹងបទចោទប្រកាន់។




នៅក្នុងសវនាការពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ ដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មនិងពិនិត្យភស្តុតាងនានា ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទ។ សវនាការនាបន្តនឹងចាប់ផ្តើមពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២។ អង្គជំនុំជម្រះនឹងពិនិត្យទៅលើរចនាសម្ព័ន្ធរដ្ឋបាល និងទម្រង់នៃទំនាក់ទំនងគ្នាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងផ្នែកបន្ទាប់បន្សំទៀតនៃតួនាទីរបស់ជនជាប់ចោទ។

នៅក្នុងសវនាការបន្ទាប់នេះ អង្គជំនុំជម្រះសាលាដំបូងនឹងសួរដេញដោល កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងសំណុំរឿង ០០១ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះមានគម្រោងសួរដេញដោលសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៥៤នាក់ទៀត។

ឯកសារនេះផ្តល់ទិន្នន័យសង្ខេបអំពីសក្ខីកម្មនៅក្នុងសវនាការដំណាក់កាលទី១ រួមទាំងសក្ខីកម្មរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី។ សូមបញ្ជាក់ថា នេះមិនមែនជាឯកសារផ្លូវការទេ។ ដើម្បីទទួលបានព័ត៌មានពិស្តារនិងលម្អិតអំពីសវនាការ សូមអានប្រតិចារិកនៃសវនាការដែលអាចរកបាននៅលើគេហទំព័ររបស់ អ.វ.ត.ក៖ http://www.eccc.gov.kh/Case002-Transcripts/km។

## សវនាការជំនុំជម្រះក្តី សំណុំរឿង ០០២

សវនាការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២ ប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ចំនួនបីរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ បានចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយផ្តើមចេញពីការធ្វើសេចក្តីសន្និដ្ឋានលើបទចោទប្រកាន់របស់សហព្រះរាជអាជ្ញាទៅលើជនជាប់ចោទទាំងបីរូប បន្ទាប់មក ជនជាប់ចោទនិងមេធាវីរបស់ខ្លួនក៏បានធ្វើសេចក្តីសន្និដ្ឋានឆ្លើយតប។

# សហព្រះរាជអាជ្ញា៖ សេចក្តីសន្និដ្ឋានលើបទចោទប្រកាន់

សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង បង្ហាញពីឧបកថាឧក្រិដ្ឋកម្មដែលអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវស្តាប់នៅក្នុងអំឡុងសវនាការជាផ្នែកៗដែលនឹងប្រព្រឹត្តទៅនាពេលខាងមុខ។ ចំណែកលោក អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិ បានបង្ហាញឲ្យឃើញពីហេតុផលដែលនាំឲ្យគាត់ជឿជាក់ថា ជនត្រូវចោទទាំងបីរូប គឺ នួន ជា, អៀង សារី និង ខៀវ សំផន មានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនេះក្នុងទម្រង់ជាសហឧក្រិដ្ឋកម្មរួម។

## ទីតាំងឧក្រិដ្ឋកម្ម

***ការជម្លៀសប្រជាជនដោយបង្ខំ (លើកទី១ និងលើកទី២)៖*** រយៈពេលមិនយូរប៉ុន្មានបន្ទាប់ពីខ្មែរក្រហមបានផ្តួលរំលំរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រួចមក ប្រជាជននៅទីក្រុងភ្នំពេញចំនួនជាងពីរលាននាក់ ត្រូវបានបង្ខំឲ្យចាកចេញទៅទីជនបទ។ ការជម្លៀសដោយបង្ខំដូចគ្នានេះបានកើតមាននៅតាមទីប្រជុំជនផ្សេងៗទៀតទូទាំងប្រទេសកម្ពុជា។



*ពលកម្មដោយបង្ខំ នៅការដ្ឋានជីកប្រឡាយ*

***ទីតាំងពលកម្មដោយបង្ខំចំនួន៥៖*** ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ យ៉ាងអមនុស្សធម៌ នៅក្នុងកងចល័តនិងសហករណ៍។ ការចោទប្រកាន់ផ្តោតទៅលើទីតាំងចំនួនប្រាំ ក្នុងនោះរួមទាំងវាលស្រែអំបិលនៅក្នុងខេត្តកំពត និងអាកាសយានដ្ឋាននៅក្នុងខេត្តកំពង់ឆ្នាំង។

***ការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិកជន៖*** របបនេះបានបង្កើតឲ្យមានការគាបសង្កត់ទៅលើសាសនាព្រះពុទ្ធនៅទូទាំងប្រទេស ចាប់ព្រះសង្ឃផ្សឹក និង ហាមប្រាមមិនឲ្យប្រតិបត្តិពិធីបុណ្យនិងជំនឿផ្សេងៗទៅតាមទម្លាប់សាសនាព្រះពុទ្ធ។

***ការរៀបការដោយបង្ខំ៖*** បុរសនិងស្ត្រីរាប់សែននាក់ត្រូវ "អង្គការ" ចាប់បង្ខំឲ្យរៀបការ រំលោភផ្លូវភេទ ធ្វើទារុណកម្ម សម្លាប់ ឬទទួលរងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងទ្រង់ទ្រាយធំ។

***ឧក្រិដ្ឋកម្មនានានៅមន្ទីរសន្តិសុខចំនួន ១១៖*** មានការជឿជាក់ថារបបនេះបានបង្កើតមន្ទីរសន្តិសុខជាង២០០កន្លែងនៅទូទាំងប្រទេស ដើម្បីចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ បុគ្គលដែលជា "ខ្មាំង"។ ការចោទប្រកាន់ផ្តោតទៅលើឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខចំនួន ១១ ក្នុងចំណោមមន្ទីរសន្តិសុខទាំងអស់ រួមទាំង មន្ទីរ ស-២១ ដែលមានទីតាំងនៅទីក្រុងភ្នំពេញ។

***អំពើប្រល័យពូជសាសន៍លើក្រុមជាតិពន្ធចាមនិងវៀតណាម៖*** ប្រជាជនចាមនៅខេត្តកំពង់ចាមនិងប្រជាជនវៀតណាមនៅខេត្តព្រៃវែងនិងស្វាយរៀង ត្រូវបានការកាប់សម្លាប់ជាប្រព័ន្ធតាមបញ្ជារបស់ថ្នាក់ដឹកនាំនៃរបបនោះ។

***ឧក្រិដ្ឋកម្មនានាក្នុងអំឡុងជម្លោះប្រដាប់អាវុធជាមួយវៀតណាម៖*** របបកម្ពុជាប្រជាធិបតេយ្យបានបើកការលុកលុយទៅក្នុងទឹកដីវៀតណាម បណ្តាលឲ្យមានមនុស្សស្លាប់និងបាត់ខ្លួនជាង ៣ម៉ឺននាក់ ហើយប្រជាជនជាង៤ម៉ឺននាក់ទៀតត្រូវបង្ខំចិត្តចាកចេញពីភូមិស្រុករបស់ខ្លួន។ ជនរងគ្រោះជាច្រើនត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ដើម្បីសួរចម្លើយនិងសម្លាប់។




***ការជម្លៀសលើកទីបី និងការបោសសម្អាតនៅភូមិភាគបូព៌ា៖*** នៅក្នុងអំឡុងពាក់កណ្តាលចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ ការបោសសម្អាតយ៉ាងរង្គាលមួយបានកើតឡើងនៅភូមិភាគបូព៌ា បណ្តាលឲ្យមនុស្សស្លាប់រហូតដល់ ២៥ម៉ឺននាក់ ហើយប្រជាជនស្ទើរតែទាំងអស់នៃភូមិភាគបូព៌ាត្រូវបានបង្ខំឲ្យផ្លាស់ទីទៅភូមិភាគផ្សេងៗទៀតនៃប្រទេសកម្ពុជា។



*ភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥*

## ផែនការសហឧក្រិដ្ឋកម្មរួមរបស់ ប.ក.ក

ជនជាប់ចោទទាំងបីរូបត្រូវបានចោទប្រកាន់ថា បានចូលរួមចំណែកនៅក្នុងការរៀបចំនិង អនុវត្តគោលនយោបាយសំខាន់ៗ ដូចខាងក្រោម៖

- ការជម្លៀសដោយបង្ខំចេញពីទីក្រុងទៅកាន់ជនបទ
- ធ្វើពលកម្មដោយបង្ខំនៅតាមបណ្តាការដ្ឋាននិងសហករណ៍
- ប្រើប្រាស់អំពើហិង្សាដើម្បីកម្ទេចខ្មាំងតាមរយៈបណ្តាញអប់រំកសាងនៅទូទាំងប្រទេស ឬមន្ទីរសន្តិសុខនានា
- ធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិកកម្ពុជា ជនជាតិចាមនិងវៀតណាម
- រៀបការដោយបង្ខំ

សហព្រះរាជអាជ្ញាបានអះអាងថា គោលនយោបាយទាំងនេះគឺចេញមកពីមេដឹកនាំរបស់ ប.ក.ក ដែលជនជាប់ចោទទាំងបីរូបមានជាប់ពាក់ព័ន្ធ។

## តួនាទីរបស់ជនជាប់ចោទ

លោកស្រី ជា លាង បានលើកឡើងថា៖ "ជនជាប់ចោទទាំងនេះគឺជាបុគ្គលមានឥទ្ធិពលខ្លាំងបំផុតនៅពីក្រោយផែនការឧក្រិដ្ឋកម្ម ព្រមទាំងអ្នកមានឆន្ទៈចូលរួមនិងគាំទ្រយ៉ាងសកម្មចំពោះផែនការនេះ"។ "ជនជាប់ចោទទាំងនេះត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះគ្រប់ឧក្រិដ្ឋកម្មទាំងអស់ដែលចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ"។ សហព្រះរាជអាជ្ញាចោទប្រកាន់ជនជាប់ចោទ ថាមានការទទួលខុសត្រូវនៅក្នុងតួនាទីរបស់ខ្លួនដូចខាងក្រោម៖

**នួន ជា:** ប្រធានសភាតំណាងប្រជាជនកម្ពុជា អនុលេខាគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ទទួលបន្ទុកកិច្ចការបក្ស ផ្នែករៀនសូត្រនយោបាយនិងបណ្តុះបណ្តាលកម្មាភិបាលបក្ស។

**អៀង សារី:** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស សមាជិកពេញសិទ្ធិមួយរូបនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា។

**ខៀវ សំផន:** ប្រធានគណៈប្រធានរដ្ឋ ប្រមុខរដ្ឋ សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា គណៈនយោបាយនៃមន្ទីរ៨៧០ និងទទួលបន្ទុកត្រួតពិនិត្យបញ្ហាពាណិជ្ជកម្មទូទាំងប្រទេស។

## គណៈកម្មាធិការអចិន្ត្រៃយ៍ នៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា




*(ដកស្រង់ចេញពីសេចក្តីសន្និដ្ឋានលើបទចោទប្រកាន់របស់សហព្រះរាជអាជ្ញា)*

# ចុងចោទ៖ ការឆ្លើយតប







## នួន ជា

*"ការចោទប្រកាន់ចំពោះខ្ញុំទាំងប៉ុន្មានសុទ្ធតែជារឿងមិនពិត។ គោលជំហរតស៊ូរបស់ខ្ញុំក្នុងបដិវត្តន៍គឺដូចបានរៀបរាប់មកជាហូរហែនេះគឺដើម្បីផលប្រយោជន៍ជាតិនិងប្រជាជនជាធំ"។*

*"ខ្ញុំសូមជម្រាបថា ការរស់នៅក្រោមការគាបសង្កត់និងឃើញភាពអយុត្តិធម៌សង្គមគ្រប់បែបយ៉ាង បានជំរុញឲ្យខ្ញុំផុសចេញនូវគំនិតលះបង់គ្រួសារដើម្បីទៅតស៊ូរំដោះជាតិមាតុភូមិពីនឹមអាណានិគម គឺការឈ្លានពានគាបសង្កត់ពីពួកចោរបរទេស លួចទឹកដី ចង់លុបបំបាត់ព្រះពុទ្ធសាសនានិងពូជសាសន៍ខ្មែរ"។*

## អៀង សារី

អៀង សារី បានអានសេចក្ដីថ្លែងការណ៍ខ្លីមួយដោយទាមទារឲ្យអង្គជំនុំជម្រះសាលាដំបូងពន្យារពេលដំណើរការនីតិវិធី និងរង់ចាំរហូតដល់ពេលដែលបញ្ហាគតិយុត្តិនានាពាក់ព័ន្ធនឹងព្រះរាជក្រឹត្យលើកលែងទោសនិងអនុគ្រោះទោស ដែលព្រះមហាក្សត្រទ្រង់ប្រោសប្រទានចំពោះរូបគាត់នៅឆ្នាំ១៩៩៦ ត្រូវបានដោះស្រាយរួចរាល់។

*"ជាមួយនឹងសេចក្ដីគោរពដ៏ជ្រាលជ្រៅនេះ ខ្ញុំបាទក៏មានសេចក្ដីអំពល់ កង្វល់ បារម្ភជាខ្លាំងដែរ ដោយសារថា អង្គជំនុំជម្រះសាលាដំបូងមិនព្រមបង្អន់ដំណើរការនីតិវិធីរហូតដល់អង្គជំនុំជម្រះតុលាការកំពូលសម្រេចលើបញ្ហានេះសិន"*។

## ខៀវ សំផន

បានរិះគន់សេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាថាជា "ការចោទប្រកាន់ស្មានៗ" និងជា "ការអះអាងដោយគ្មានភ័ស្តុតាងនិងផ្សំរឿងនេះបន្តិចរឿងនោះបន្តិច"។

*"ខ្ញុំនៅតែសង្ឃឹមថា យ៉ាងហោចណាស់តុលាការនេះក៏អាចជាឱកាសឲ្យខ្ញុំបានពន្យល់ដល់ជាតិយើង ដើម្បីយល់ថា ហេតុម្ដេចបានជាខ្ញុំដែលជាអ្នកកាន់តំណែងខ្ពស់ជាផ្លូវការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំនៅតែថាមិនដែលបានចូលរួមសម្រេចកិច្ចការអ្វីធំដុំសោះ ហើយមិនបានដឹងទាល់តែសោះអំពីអ្វីដែលបានកើតមាននៅក្នុងប្រទេសយើងពីពេលនោះ"*។

# សវនាការលើអង្គសេចក្ដី ពីថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០១១ ដល់ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

## ជនជាប់ចោទ អៀង សារី



ជនជាប់ចោទ អៀង សារី អាយុ៨៦ឆ្នាំ ត្រូវបានអង្គជំនុំជម្រះកោះហៅទៅអង្គុយក្នុងរង្វង់ក្រចកសេះជាលើកដំបូងនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ។ បន្ទាប់ពីបានឆ្លើយសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ អៀង សារី បានអានសេចក្ដីប្រកាសខ្លីមួយដែលមានខ្លឹមសារថា គាត់នឹងមិនឆ្លើយនឹងសំណួរណាផ្សេងទៀតឡើយ រហូតដល់ចប់នីតិវិធីតុលាការ។

*"លោកប្រធានជាទីគោរព សូមគោរពលោក លោកស្រីចៅក្រមទាំងអស់! ខ្ញុំសូមប្រើប្រាស់សិទ្ធិរបស់ខ្ញុំ ដោយរក្សាសិទ្ធិ នៅស្ងៀមមិនឆ្លើយតបនឹងសំណួរទាំងឡាយនាពេលនេះ។ សិទ្ធិនេះមានចែងនៅក្នុងវិធានផ្ទៃក្នុង និងមាត្រា ៣៦ និង ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយខ្ញុំមានបំណងប្រើប្រាស់សិទ្ធិនេះនៅក្នុងការជំនុំជម្រះទាំងមូល ហើយមិនមានបំណងឆ្លើយតបទៅនឹងសំណួរណាមួយឡើយ"*។

## ជនជាប់ចោទ នួន ជា

### សវនាការនៅថ្ងៃទី ៥, ៦, ១៣-១៥ ខែធ្នូ ឆ្នាំ២០១១



នួន ជា អាយុ៨៥ឆ្នាំ គឺជាជនជាប់ចោទទី១ ដែលអង្គជំនុំជម្រះសាលាដំបូងកោះហៅឲ្យផ្តល់សក្ខីកម្ម ក្នុងអំឡុងសវនាការលើអង្គសេចក្តី។ ខាងក្រោមជាសេចក្តីសង្ខេបសក្ខីកម្មរបស់ជនជាប់ចោទ នួន ជា៖

- គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តថៃនៅឆ្នាំ១៩៥០។ បន្ទាប់ពីបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ គាត់បានចូលរួមជាមួយនឹងបក្សកុម្មុយនីស្តឥណ្ឌូចិន និងបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរនៅឆ្នាំ១៩៥១ ដែលជាសាខារបស់បក្សកុម្មុយនីស្តឥណ្ឌូចិន។
- នៅឆ្នាំ១៩៦០ គាត់, ទូ សាមុត និង សាឡុត ស ហៅ ប៉ុល ពត បានបង្កើតបក្សពលករខ្មែរដើម្បីរំដោះខ្លួនចេញពីការគ្រប់គ្រងរបស់វៀតណាម និងក្រោយមកបានកែប្រែឈ្មោះបក្សនេះទៅជាបក្សកុម្មុយនីស្តកម្ពុជា។ គាត់គឺជាអនុលេខាធិការនៃបក្សពលករខ្មែរចាប់ពីដំបូង ទទួលខុសត្រូវផ្នែកអប់រំ មិនមែនផ្នែកយោធាទេ។
- នួន ជា បាននិយាយថា ៖ *"ចំពោះអ្វីទាំងប៉ុន្មានដែលបានចោទនោះសុទ្ធតែជារឿងមិនពិត មិនត្រូវ ពីព្រោះថា ខ្ញុំបានលះបង់ដើម្បីទៅតស៊ូរំដោះ ជាតិមាតុភូមិ"*។
- ជម្លោះប្រដាប់អាវុធ៖ លក្ខន្តិកៈបក្សត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទី១ នៅឆ្នាំ១៩៦០ ដោយផ្អែកលើគោលការណ៍ "ប្រជាធិបតេយ្យប្រមូលផ្តុំ"។
- បដិវត្តន៍គឺជាការតស៊ូនយោបាយពីដំបូង ហើយកងទ័ពបដិវត្តន៍កម្ពុជា (RAK) មានអត្ថិភាពនៅខែមករា ឆ្នាំ១៩៦៨។ មុនពេលបង្កើតកងទ័ពបដិវត្តន៍កម្ពុជា អង្គភាពការពារសម្ងាត់មួយមានភារកិច្ចការពារ កម្មាភិបាលនៅពេលកម្មាភិបាលចុះបេសសកម្ម និងកម្ទេចគិញនៅពេលកាលៈទេសៈតម្រូវឲ្យធ្វើដូចនេះ។
- ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ៖ សេចក្តីសម្រេចចុងក្រោយក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំវិសាមញ្ញមួយរបស់គណៈកម្មាធិការកណ្តាល និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្ស នៅឆ្នាំ១៩៧៤។ គណៈកម្មាធិការទាំងពីរបានកំណត់ថា ដើម្បីបញ្ចៀសការស្លាប់មនុស្សបន្ថែមទៀត ត្រូវតែជម្លៀសប្រជាជន។ ប្រជាជនត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងសហករណ៍ផ្សេងៗតាមខេត្ត ដែលនៅទីនោះ ប្រជាជនទទួលបានអាហារបីពេលក្នុងមួយថ្ងៃ និងមានបង្អែមហូបម្តងក្នុងមួយសប្តាហ៍។
- សហករណ៍មួយចំនួនមានអាហារមិនគ្រប់គ្រាន់សម្រាប់បរិភោគ ដោយសារតែ "សមាសភាពមិនល្អ" ដែលមានបំណងចង់បំផ្លិចបំផ្លាញបក្ស។ នួន ជា បាននិយាយថា សមាសភាពមិនល្អទាំងនោះត្រូវបានកម្ទេចចោល។

### ថ្ងៃទី ១១-១២ និង ៣០-៣១ ខែមករា ឆ្នាំ២០១២

- ការជ្រើសរើសនិងប្រមូលកម្លាំង៖ របបខ្មែរក្រហមផ្តោតការធ្វើបដិវត្តន៍របស់ខ្លួននៅជនបទ ដោយសារប្រជាជនក្រីក្រងាយស្រួលបញ្ចុលមនោគមន៍វិជ្ជា។ របបនោះមិនបានបង្កើតកម្លាំងទ័ពឈ្លបដោយខ្លួនឯងទេ ប៉ុន្តែ "ប្រជាជនខ្លួនឯងបង្កើតជាក្រុមៗដើម្បីការពារខ្លួន"។
- គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា "មិនបានគិតអំពី" អាយុជីវិតរបស់អ្នកជំងឺចូលព្យាបាលនៅមន្ទីរពេទ្យក្នុងអំឡុងពេលជម្លៀសទេ ពីព្រោះពួកគេជាប់រវល់គិតអំពីការគំរាមកំហែងពីកម្លាំងអាមេរិកឬវៀតណាម និងបញ្ហាកង្វះខាតស្បៀងអាហារ។
- ខ្មែរក្រហមមិនមានគោលដៅលុបបំបាត់រូបិយវត្ថុឡើយ ប៉ុន្តែមានការដោះដូរទំនិញគ្រប់គ្រាន់ ដូច្នេះមិនចាំបាច់មានរូបិយវត្ថុឡើយ។ បក្សជឿជាក់ថា បើសិនជាពួកគេ "ឈប់ប្រើលុយបណ្តោះអាសន្នសិននោះ" ពួកគេនឹងអាចជៀសផុតពីបញ្ហាដែលបង្កឡើងដោយគិញបង្កប់របស់អាមេរិកនិងវៀតណាម ដែលអាចប្រើប្រាស់ឬជះឥទ្ធិពលលើកម្មាភិបាលខ្មែរក្រហមតាមរយៈការផ្តល់សំណូកជាប្រាក់។
- នួន ជា បានច្រានចោលសេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាបីបួនលើកថា គាត់មិនបានជំនួស ប៉ុល ពត ក្នុងអំឡុងពេល ប៉ុល ពត ឈឺនោះទេ។
- នួន ជា បានចោទសួរដដែលៗអំពីយថាភាពនៃឯកសារថតចម្លងដែលបានដាក់នៅចំពោះមុខគាត់នៅក្នុងសវនាការ ដោយស្នើសុំមើលឯកសារដើម មុននឹងគាត់ផ្តល់ការពន្យល់ទាក់ទងនឹងឯកសារទាំងនោះ។ តុលាការបានសម្រេចថាឯកសារថតចម្លងទាំងនោះមានយថាភាពគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងតុលាការបាន ប៉ុន្តែ នួន ជា នៅតែទទូចថា៖

*"តើឲ្យខ្ញុំជឿទុកចិត្តលើតុលាការមួយរយភាគរយបានទេ? បើមិនឲ្យខ្ញុំមើលឯកសារដែលឯកសារពិតឲ្យខ្ញុំឃើញផងមើល៍!...ខ្ញុំទទូចហើយទទូចទៀត...ហើយយកឯកសារឲ្យខ្ញុំមើលមើល៍!"*

## ជនជាប់ចោទ នួន ជា

### សវនាការថ្ងៃទី ០៨, ០៩, ១៦ ខែកុម្ភៈ ឆ្នាំ ២០១២



- នួន ជា មិនបានចុះទៅកាន់សហករណ៍ញឹកញាប់ទេ។ នៅពេលគាត់ចុះទៅ គាត់បានកត់សម្គាល់ឃើញថា មានប្រជាជនមួយចំនួនខ្វះស្បៀងអាហារ ខណៈដែលប្រជាជនផ្សេងៗទៀតមានការហូបចុកគ្រប់គ្រាន់។
- គាត់មិនបានដឹងឮអ្វីច្រើនពីបញ្ហាពាក់ព័ន្ធនឹងយោធានោះទេ ប៉ុន្តែគាត់មានការជឿជាក់ថា អាវុធទាំងអស់ដែលប្រទេសចិនបានផ្តល់ឲ្យគឺផ្តល់ឲ្យ “ដោយគ្មានលក្ខខណ្ឌ” អ្វីនោះទេ។
- គាត់មិនមែនជាសមាជិកនៅក្នុងគណៈកម្មាការយោធាឡើយ។
- ពាក់ព័ន្ធនឹងការគ្រប់គ្រងរបស់ខ្មែរក្រហមទៅលើប្រជាជនថ្នាក់មូលដ្ឋាន គាត់បាននិយាយថា៖ “*នៅក្នុងសង្គ្រាម យើងចាំបាច់ត្រូវតែប្រមូលផ្តុំប្រជាជន ព្រោះថា បើយើងគ្រប់គ្រងប្រជាជន ប្រជាជននឹងនៅខាងយើង បន្ទាប់មកប្រជាជនទាំងនោះចូលរួមគាំទ្រយើង។ ប្រសិនបើប្រជាជនទាំងនោះស្ថិតនៅក្នុងដៃរបស់ខ្មាំងសត្រូវ នោះពួកគេអាចនឹងជួយដល់ខ្មាំងសត្រូវ...។ ប្រជាជនត្រូវតែប្រមូលផ្តុំ គ្រប់គ្រងឲ្យបានកាន់តែខ្លាំងគឺកាន់តែប្រសើរ។ យើងខ្ញុំចាំបាច់ត្រូវតែកៀងគរប្រជាជនឲ្យដាច់ចេញពីខ្មាំងសត្រូវ ដើម្បីទុកឲ្យពួកខ្មាំងសត្រូវរស់នៅតែឯង គ្មានប្រជាជនរស់ក្រោមការគ្រប់គ្រងរបស់ខ្មាំង*”។
- លោក នួន ជា និយាយថា គាត់មានការឈឺចាប់ដោយឃើញការរំលោភបំពានទៅលើបុគ្គលិករាជការ ដែលស្ថិតក្រោមការត្រួតត្រារបស់អភិជននាសម័យអាណានិគមបារាំង និងការរំលោភបំពានទៅលើប្រជាជនកម្ពុជានៅតាមភូមិ ពីសំណាក់ទាហានបរទេសបារាំងកាលពីគាត់នៅជាយុវជន។ នៅទីបំផុត មូលហេតុនេះបានជំរុញឲ្យរូបគាត់ចូលរួមជាមួយចលនាបដិវត្តន៍កុម្មុយនីស្ត។
- នួន ជា បានបន្តទាមទាររកច្បាប់ដើមនៃរាល់ឯកសារចម្លងដែលត្រូវបានលើកយកមកបង្ហាញនៅក្នុងតុលាការ បន្ថែមពីលើខ្សែអាត់សំឡេងដើមនៃបទសម្ភាសន៍ស្តាប់យកចម្លើយដែលបានថតទុកនោះទៀត។ លោក មីឃ្លៀល ផេស្តមេន មេធាវីការពារក្តីរបស់ នួន ជា មានប្រសាសន៍ថា សំណើទាំងឡាយរបស់កូនក្តីរបស់ខ្លួនគួរចាត់ទុកថាជាការតវ៉ាចំពោះយថាភាពរបស់ឯកសារទាំងឡាយដែលបានលើកយកមកបង្ហាញ។
- នៅក្នុងសេចក្តីថ្លែងការណ៍ខ្លីមួយកាលពីថ្ងៃទី១៦ ខែកុម្ភៈ នួន ជា បានស្នើសុំដល់អង្គជំនុំជម្រះមិនឲ្យធ្វើសេចក្តីសម្រេចទៅលើផ្នែកនៃសវនាការពាក់ព័ន្ធនឹងប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ ព្រោះគាត់ជឿជាក់ថា ប្រធានបទពាក់ព័ន្ធមួយចំនួនមិនត្រូវបានតុលាការពិនិត្យមើល ហើយសាក្សីដែលជាប់ពាក់ព័ន្ធមួយចំនួនទៀតក៏មិនត្រូវបានកោះហៅមកសួរដែរ។

## សាក្សី វ៉ាន់ថាន់ ពៅដារ៉ា

### ថ្ងៃទី២៣-២៥ ខែ មករា ឆ្នាំ២០១២

លោក វ៉ាន់ថាន់ ពៅដារ៉ា អាយុ ៤០ឆ្នាំ ត្រូវបានកោះហៅធ្វើជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនាមលោកជាអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាឃ្លាំងផ្ទុកឯកសារប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម។ មជ្ឈមណ្ឌលនេះបានផ្តល់ឯកសារចំនួនប្រហែល ៥០០.០០០ ទំព័រ ដល់ អ.វ.ត.ក។

លោក ពៅដារ៉ា បានឆ្លើយទៅនឹងសំណួរទាក់ទងនឹងទម្រង់នៃការប្រមូលនិងការរៀបចំទុកដាក់ឯកសារ ការអប់រំ និងការបណ្តុះបណ្តាលបុគ្គលិក ទម្រង់ការបញ្ជាក់យថាភាពនៃឯកសារដោយ DC-Cam និងប្រភពជំនួយហិរញ្ញវត្ថុដែលបានផ្តល់ឲ្យ DC-Cam។

- លោក វ៉ាន់ថាន់ ពៅដារ៉ា បានថ្លែងថា៖ ទិសដៅចម្បងរបស់ DC-Cam គឺដើម្បី “ស្វែងរកការពិត” ទាក់ទងនឹងរបបខ្មែរក្រហម លើកទឹកចិត្តឲ្យមានការអប់រំ ផ្តល់ឯកសារប្រវត្តិសាស្ត្រដល់អ្នកស្រាវជ្រាវ ជួយអ្នករស់រានមានជីវិតទទួលបានយុត្តិធម៌និងស្វែងរកសាច់ញាតិដែលបាត់ខ្លួន និងលើកស្ទួយដល់ការបង្រួបបង្រួមជាតិ។
- ជាទូទៅ DC-Cam ប្រមូលព័ត៌មាន ប៉ុន្តែមិនធ្វើការវិភាគទៅលើឯកសារទេ។

មេធាវីការពារក្តីបានលើកឡើងថា លោក វ៉ាន់ថាន់ ពៅដារ៉ា មិនបានផ្តល់ព័ត៌មានលម្អិតអំពី DC-Cam នៅក្នុងសក្ខីកម្មរបស់ខ្លួនទេ ហើយបានស្នើឲ្យកោះហៅលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មកផ្តល់សក្ខីកម្មក្នុងខែកុម្ភៈ។ លោក Jasper Pauw សហមេធាវីការពារក្តីលោក នួន ជា បានថ្លែងថា “*ប្រសិនបើលោក ឆាំង យុ មិនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទេនោះ ជំហររបស់យើងគឺមិនទទួលស្គាល់ឯកសារទទួលបានពី DC-Cam ថាជាឯកសារមានយថាភាពនិងអាចទុកចិត្តបានទេ*”។

## ជនជាប់ចោទ ខៀវ សំផន

### សវនាការនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១
### ថ្ងៃទី១២ និងទី១៦ ខែមករា និងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១២



អតីតប្រមុខរដ្ឋ ខៀវ សំផន អាយុ ៨០ឆ្នាំ មានបំណងប្រើប្រាស់សិទ្ធិរបស់គាត់ មិនឆ្លើយតបទៅនឹងសំណួរទាក់ទងនឹងបទចោទប្រឆាំងនឹងគាត់ ក៏ប៉ុន្តែគាត់បានឆ្លើយសំណួរមួយចំនួនទាក់ទងនឹងអំពីប្រវត្តិផ្ទាល់ខ្លួនរបស់គាត់ និងបានអានសេចក្តីថ្លែងការណ៍មួយ។

- គាត់ពុំមានឈ្មោះហៅក្រៅថា "ខាង" ទេ ហើយគាត់មិនធ្លាប់ជួបជាមួយនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតលេខាមន្ទីរ ស-២១ ទេ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលការណ៍នេះផ្ទុយទៅនឹងការអះអាងរបស់ ឌុច។
- នៅពេលគាត់នៅទីក្រុងប៉ារីស នៅឆ្នាំ១៩៥៣ គាត់បានជួបជាមួយនឹង អៀង សារី មិនមែន សឡុត ស ហៅ ប៉ុល ពត ទេ។
- បន្ទាប់ពីបានចូលរួមក្នុងរង់ម៉ាក្សស៊ីសក្នុងទីក្រុងប៉ារីសភ្លាម គាត់បានទៅសិក្សានៅខេត្ត ម៉ុងប៉េលីយេ។
- ខៀវ សំផន បានប្រាប់អង្គជំនុំជម្រះថា *"នៅក្នុងនិក្ខេបបទរបស់ខ្ញុំ ខ្ញុំមិនបានថាឲ្យលុបបំបាត់ការប្រើប្រាស់លុយនោះទេ ហើយក៏មិនបានស្នើឲ្យបំបាត់កម្មសិទ្ធិឯកជនទេ ហើយក៏មិនបាននិយាយពីការជម្លៀសប្រជាជនចេញពីទីក្រុងដែរ"*។
- គាត់បានចូលរួមជាមួយនឹងបក្សកុម្មុយនីស្តបារាំងនៅឆ្នាំ១៩៥៥ ដោយមានជំនឿថា ការប្រយុទ្ធជាមួយនឹងអាណានិគមរបស់បក្សនេះ នឹងជួយពន្លឿនឯករាជ្យភាពនៅប្រទេសកម្ពុជា។
- គាត់បានរត់ចូលព្រៃនៅឆ្នាំ១៩៦៧ បន្ទាប់ពីត្រូវបានគំរាមកំហែងអំពីការចាប់ខ្លួននិងបញ្ជូនទៅតុលាការសឹកពីបទ ធ្វើជាមេដឹកនាំក្រុមបះបោរនៅសំឡូត។ បន្ទាប់ពីបានរត់ចូលព្រៃ គាត់ចូលរួមជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៦៩ ដោយសារសន្តិសុខផ្ទាល់ខ្លួន មិនមែនដោយសារគាត់មានជំនឿលើ "ការតស៊ូ" ឡើយ។ គាត់បានអះអាងថា គាត់បានដឹងតាមវិទ្យុ អំពីការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប៉ុន្តែមិនបានដឹងថាគាត់ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីការពារប្រទេសឡើយ។
- គាត់បានបញ្ជាក់ម្តងហើយម្តងទៀតថា គាត់គ្មានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តទេ ដោយចាត់ទុកខ្លួនឯងថាជា "ឧបនាយករដ្ឋមន្ត្រីខ្យល់ និងរដ្ឋមន្ត្រីការពារប្រទេសខ្យល់"។ គាត់បាននិយាយថា គាត់ក្លាយជាសមាជិកគណៈកម្មាធិការកណ្តាលនៃបក្សកុម្មុយនីស្តកម្ពុជា ពីព្រោះតែតួនាទីរបស់គាត់ជាអ្នកទាក់ទងជាមួយនឹងសម្តេច នរោត្តម សីហនុ។
- *"លក្ខខណ្ឌដែលគេឲ្យខ្ញុំចូលគណៈមជ្ឈិមគឺគេអនុគ្រោះទេ។ ខ្ញុំមិនពេញលក្ខណៈសម្បត្តិដើម្បីចូលបក្សមជ្ឈិមទេ ព្រោះខ្ញុំជាកូនសក្តិភូមិ"*។

## សាក្សី ឡុង នរិន្ទ

### សវនាការនៅថ្ងៃទី ៧, ៨, ១៤, ១៥ ខែ ធ្នូ ឆ្នាំ ២០១១

លោក ឡុង នរិន្ទ អាយុ៧៣ឆ្នាំ រស់នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ បានផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះសាលាដំបូងតាមរយៈប្រព័ន្ធសោតទស្សន៍ពីលំនៅស្ថានរបស់លោក ដោយសារលោកមានបញ្ហាសុខភាពពុំអាចមានវត្តមាននៅក្នុងសវនាការ។

- លោកបានទៅសិក្សានៅក្នុងប្រទេសឆេកូស្លូវ៉ាគី និងបានធ្វើការនៅទីក្រុងប៉េកាំង ហើយបានជួប អៀង សារី នៅទីនោះ។ បន្ទាប់មកលោកបានទៅធ្វើការនៅវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជាដែលគ្រប់គ្រងដោយ អៀង ធីរិទ្ធ នៅទីក្រុងហាណូយ។
- តាមបញ្ជាពី នួន ជា និង ខៀវ សំផន លោក នរិន្ទ បានទៅខេត្តព្រះវិហារដើម្បីស្វែងយល់អំពីតម្រូវការរបស់ប្រជាជន ហើយវិលត្រឡប់មកទីក្រុងភ្នំពេញវិញនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥។
- លោក នរិន្ទ បានបញ្ជាក់ថា អៀង សារី បានបញ្ជាមិនឲ្យយកនរណាម្នាក់ចេញពីក្រសួងការបរទេសឡើយ ហើយមិនឲ្យធ្វើការសម្រេចចិត្តណាមួយឡើយនៅពេលគាត់មិននៅក្នុងក្រសួង។ នៅពេលបុគ្គលិកក្នុងក្រសួងបាត់ខ្លួន លោក ឡុង នរិន្ទ ត្រូវបានគេប្រាប់ថា បុគ្គលិកទាំងនោះត្រូវបានបញ្ជូនទៅរៀនសូត្រ។ មួយរយៈពេលក្រោយមក លោកបានដឹងថា បុគ្គលិកទាំងនោះមិនមែនទៅរៀនសូត្រទេ ប៉ុន្តែត្រូវបញ្ជូនទៅការដ្ឋាន ឬទៅមន្ទីរ ស-២១។

លោក ឡុង នរិន្ទ មានការលំបាកក្នុងការឆ្លើយសំណួរ ហើយចម្លើយរបស់គាត់មិនស៊ីសង្វាក់គ្នាជាមួយនឹងបទសម្ភាសន៍ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់តុលាការកាលពីឆ្នាំ២០០៧។ ប៉ុន្តែលោកបានទទួលស្គាល់ថា ពេលវេលាធ្វើឲ្យលោកមានការភ័ន្តច្រឡំអង្គហេតុមួយចំនួន។

## ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ហ្វិត

### សវនាការនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១

លោក ក្លាន ហ្វិត អាយុ៦៥ឆ្នាំ មកពីភូមិតាឡាវ ខេត្តរតនគិរី។

- លោកបានចូលរួមជាមួយនឹងខ្មែរក្រហមនៅមុនរដ្ឋប្រហារទម្លាក់ លន់ នល់ ក្នុងតួនាទីជានីរសារ អ្នករៀបចំកិច្ចប្រជុំ និងអ្នកសាងសង់ផ្ទះ។ ក្រោយមក លោកត្រូវបានតែងតាំងជាប្រធានឃុំ និងធ្វើការងារពាក់ព័ន្ធនឹងសេដ្ឋកិច្ច ការអប់រំ និងការការពារ។ លោកបានចូលរួមប្រជុំចំនួនពីរដងដែលមាន អៀង សារី ជាប្រធានអង្គប្រជុំ។
- បន្ទាប់ពីខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ លោក ក្លាន ហ្វិត ត្រូវបានអញ្ជើញឲ្យទៅភ្នំពេញចំនួនពីរដង ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលនយោបាយដែលបង្រៀនដោយ នួន ជា។ នៅឆ្នាំ១៩៧៦ លោកត្រូវបានតែងតាំងជាអនុលេខាស្រុក ២១ ក្នុងភូមិភាគឦសាន ដែលគ្រប់ដណ្តប់ឃុំចំនួន ៦។
- តំបន់របស់លោកពុំមានសហករណ៍ឡើយរហូតដល់ឆ្នាំ១៩៧៦ ទើបប្រជាជនត្រូវបានបង្គាប់ឲ្យបរិភោគរួមគ្នា និងត្រូវបានហាមឃាត់មិនឲ្យប្រតិបត្តិសាសនានិងជំនឿលើអារក្សអ្នកតា។

### សវនាការថ្ងៃទី ១០-១១ ខែមករា ឆ្នាំ២០១២

- លោក ក្លាន ហ្វិត បានថ្លែងថា គាត់បានចូលចលនាបដិវត្តន៍ដោយសារការភ័យខ្លាច។ គាត់ "ខ្លាចអង្គការ"។
- គាត់បានជួប ប៉ុល ពត, អៀង សារី និងនួន ជា ដោយផ្ទាល់ ក្នុងអំឡុងពេលគាត់ចូលរួមក្នុងចលនាបដិវត្តន៍។
- នៅពេលសួរថា ហេតុអ្វីបានជាគាត់ចង់និយាយនៅចំពោះមុខតុលាការ គាត់បានឆ្លើយថា៖

"*ចង់បានអី ចង់បានរស់។ ឧទាហរណ៍ដូចខ្ញុំឈប់ ខ្ញុំចង់បានរស់ បើថា ការអាក្រក់ការស៊ីដូចធ្វើ មិនមែនធ្វើខ្លួនឯង។ ធ្វើដោយសារអ៊ីៗតាៗហ្នឹងហើយ នាំខ្ញុំធ្វើ*"។

## សាក្សី ឆាំង យុ

### សវនាការថ្ងៃទី ០១, ០២, ០៦ ខែកុម្ភៈ ឆ្នាំ២០១២

លោក ឆាំង យុ អាយុ៥១ឆ្នាំ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលជាទីកន្លែងរក្សាទុកឯកសារជាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងបានជួយជ្រោមជ្រែងដល់ការិយាល័យនានារបស់ អ.វ.ត.ក ដើម្បីប្រមូលឯកសារភ័ស្តុតាង។ លោក ឆាំង យុ ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងរៀបចំឯកសារខ្មែរក្រហម របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

លោក ឆាំង យុ ត្រូវបានសាកសួរអំពីប្រវត្តិការងាររបស់គាត់ ប្រភពថវិការបស់មជ្ឈមណ្ឌលកម្ពុជា និងប្រភពរបស់ឯកសារ នីតិវិធីដែលបុគ្គលិក DC-Cam ប្រើក្នុងការរៀបចំឯកសារ ព្រមទាំងវិធីសាស្ត្រក្នុងការផ្ទៀងផ្ទាត់យថាភាពនៃឯកសារ។ ខាងក្រោមជាសេចក្តីសង្ខេបសក្ខីកម្មរបស់លោក ឆាំង យុ៖

- លោក ឆាំង យុ បានពិនិត្យមើលឯកសារទាំងអស់ដែលប្រមូលបាន មុនពេលដែលឯកសារទាំងនោះត្រូវបានរៀបចំទុកដាក់។
- មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលឯកសារគ្រប់ប្រភេទដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនគិតពីប្រធានបទ ឬការលម្អៀងផ្នែកនយោបាយនោះឡើយ រួមទាំងឯកសារជំនាន់ក្រោយៗមកទៀតជាច្រើនដែលពាក់ព័ន្ធនឹងរបបនោះ។
- មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានផ្អែកទៅលើតែការពិសោធន៍ផ្នែកបច្ចេកទេសដើម្បីបញ្ជាក់ពីអាយុកាលរបស់ឯកសារទាំងនោះទេ ប៉ុន្តែបានប្រើប្រាស់ចំណេះដឹងនិងជំនាញដែលទទួលបានតាមរយៈការប្រឹក្សាយោបល់ជាមួយអ្នកជំនាញនិងបុគ្គលិកមកពីមជ្ឈមណ្ឌលឯកសារដទៃទៀត។
- ឆ្លើយតបទៅនឹងសំណួរជាច្រើនដែលសហមេធាវីការពារក្តីបានចោទសួរអំពីភាពលម្អៀងដែលអាចកើតមាននៅក្នុងចំណោមបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទៅលើជនជាប់ចោទក្នុងសំណុំរឿង ០០២ គាត់មានប្រសាសន៍ថា៖ "*យើងខ្ញុំចង់បានតុលាការមួយដែលយុត្តិធម៌និងមិនលម្អៀង។ ដោយសារមូលហេតុនេះ យើងខ្ញុំគោរពទៅតាមគោលការណ៍ដែលចែងពីសិទ្ធិរបស់ជនជាប់ចោទ*"។
- លោក ឆាំង យុ មានប្រសាសន៍ថា រូបគាត់ផ្ទាល់ និងសមាជិកនៅក្នុងក្រុមគ្រួសាររបស់លោកជាច្រើនរូបទៀត បានទទួល "ការគំរាមកំហែងដោយសម្ងាត់" ជាច្រើន នៅក្នុងឆ្នាំ១៩៩៩ រួមមានទាំងលិខិតមួយច្បាប់ពី អៀង ធីរិទ្ធ ផងដែរ។ គាត់មានប្រសាសន៍ថា៖ "*មានការគម្រាមកំហែងមកលើប្អូនស្រីរបស់ខ្ញុំ ឲ្យគាត់ប្រាប់ខ្ញុំឲ្យបញ្ឈប់សកម្មភាពអស់ទាំងនេះ ប៉ុន្តែខ្ញុំមិនបានធ្វើតាមការគំរាមកំហែងនោះទេ។ ការស្រាវជ្រាវដើម្បីការផ្សះផ្សាគឺមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា*"។

## សាក្សី ប្រាក់ យុត

### សវនាការថ្ងៃទី ២៥-២៦ និង ទី៣០ ខែមករា ឆ្នាំ២០១២

អ្នកស្រី ប្រាក់ យុត អាយុ ៦៧ ឆ្នាំ ត្រូវបានកោះហៅឲ្យធ្វើជាសាក្សីផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់គាត់ជាកម្មាភិបាលថ្នាក់កណ្តាលក្នុងរបបខ្មែរក្រហម។ អ្នកស្រីត្រូវបានសួរសំណួរអំពីខ្សែសង្វាក់នៃការបញ្ជាក្នុងជួរកម្មាភិបាលខ្មែរក្រហម រចនាសម្ព័ន្ធដឹកនាំទូទៅក្នុងរបបកម្ពុជាប្រជាប្រជាធិបតេយ្យ ការធ្វើរបាយការណ៍ទៅថ្នាក់លើ និងការដឹងឮរបស់គាត់អំពីមន្ទីរសន្តិសុខនិងមន្ទីរកែប្រែ។

- គាត់ក្លាយជាសមាជិកគណៈតំបន់ក្នុងខេត្តកំពត ក្នុងឆ្នាំ១៩៧៣ ហើយត្រូវបានដំឡើងឋានៈជាលេខាស្រុកកំពង់ចាមក្នុងឆ្នាំ១៩៧៧។
- គាត់មានភារកិច្ចអប់រំប្រជាជនអំពីការសាងសង់ប្រឡាយនិងទំនប់ និងកសាងអ្នកមាន "ទោសស្រាល"។ គាត់បដិសេធថា គាត់មិនបានដឹងដោយផ្ទាល់អំពីការសម្លាប់មនុស្សទេ។ គាត់បាននិយាយថាគាត់បានឃើញប្រជាជនដែលត្រូវបានជម្លៀសពីទីក្រុងឆ្លងកាត់តំបន់របស់គាត់ ប៉ុន្តែគាត់មិនបានយកចិត្តទុកដាក់ខ្លាំងចំពោះអ្នកទាំងនោះទេ ពីព្រោះគាត់ "ជាប់ធ្វើការជាមួយប្រជាជន"។
- គាត់បានឮឈ្មោះខៀវ សំផន, នួន ជា និង អៀង សារី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនដែលបានជួបពួកគេ និងមិនដឹងអំពីភារកិច្ចរបស់ពួកគេទេ។
- ប្តីរបស់ ប្រាក់ យុត ត្រូវអង្គការចាប់ខ្លួន ហើយថែមទាំងឲ្យដំណឹងដល់គាត់ជាមុនទៀត។ អ្នកស្រីប្រាក់ យុត បានថ្លែងថា៖

*"គឺមានការណែនាំរបស់ខាងលើ ពេលចាប់ប្តី។ ចាប់ប្តី បើសិនជាខ្ញុំមានការប្រឆាំងឬទំនាស់ គឺខ្ញុំមិនហ៊ានដែរ ព្រោះសម័យនោះ លោកក៏ដឹងដែរថា ខ្ញុំមិនហ៊ាននិយាយអីទាំងអស់ និយាយរួមគឺថាគេបញ្ជាម៉េចគឺធ្វើទៅតាមបញ្ជារបស់ថ្នាក់លើព្រោះអត់ហ៊ាន។ នេះខ្ញុំសូមរាយការណ៍ស្មោះត្រង់អ៊ីចឹងតែម្តង ព្រោះខ្ញុំអត់ហ៊ាននិយាយអីទេ ព្រោះគាត់ប្រាប់មក អត់ហ៊ាននិយាយជាមួយប្តីផងហ្នឹង។ នេះខ្ញុំសូមជម្រាបដោយការស្មោះត្រង់ ព្រោះថាកាលនោះខ្ញុំមិនហ៊ាននិយាយអីក្រៅផ្លូវការដែលគាត់ណែនាំទេ ព្រោះកាលណាគេណែនាំម៉េច គឺខ្ញុំធ្វើអ៊ីចឹង។ ហើយកាលណាខ្ញុំនិយាយទៅខុស ប្តីខ្ញុំរត់បាត់ ខ្ញុំមិនរឿងអ៊ីចឹងខ្ញុំអត់ហ៊ាននិយាយ"*។

អ្នកស្រី ប្រាក់ យុត មានការភ័ន្តច្រឡំកាលបរិច្ឆេទនៃព្រឹត្តិការណ៍ជាច្រើន ហើយសក្ខីកម្មរបស់គាត់នៅក្នុងពេលសវនាការមិនស៊ីសង្វាក់នឹងចម្លើយមួយចំនួនដែលគាត់ផ្តល់ឲ្យអ្នកស៊ើបអង្កេតនៅពេលមុន។ ក្នុងស្ថានភាពនោះ គាត់សូមទទួលយកចម្លើយដែលគាត់ផ្តល់ឲ្យអ្នកស៊ើបអង្កេត។ ក្នុងពេលសួរសំណួរសាក្សី ប្រាក់ យុត មេធាវីការពារក្តីលោក នួន ជា បានថ្លែងថា អ្នកស្រី ប្រាក់ យុត ហាក់បីដូចជាមានការស្ទាក់ស្ទើរក្នុងការផ្តល់សក្ខីកម្មទាក់ទងនឹងអតីតកម្មាភិបាលខ្មែរក្រហមមួយចំនួន ហើយបានសន្និដ្ឋានថា អ្នកស្រី ប្រាក់ យុត ប្រហែលជាទទួលរងឥទ្ធិពលពីអ្នកមានអំណាចពីខាងក្រៅក្នុងការផ្តល់សក្ខីកម្មរបស់គាត់។ អ្នកស្រី ប្រាក់ យុត បានឆ្លើយតបថា៖

*"ខ្ញុំសូមបញ្ជាក់ថា ការខ្ញុំឡើងមកសវនាការនេះអត់មានអ្នកណាគំរាមកំហែងទេ។ គឺខ្ញុំឡើងមកនិយាយ បើខ្ញុំចងចាំប៉ុនណា ខ្ញុំនិយាយប៉ុណ្ណឹង តែរឿងមិនដឹងគឺខ្ញុំអត់ដឹង។ ហេតុនេះ ខ្ញុំមិនមានអ្នកណាគំរាមកំហែងខ្ញុំមិនឲ្យនិយាយទេ។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង"*។

## ដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន

### សវនាការថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១ និងថ្ងៃទី១០ ខែមករា ឆ្នាំ២០១២

លោក រម៉ាម យុន អាយុ ៧០ឆ្នាំ មកពីភូមិកាជុត ស្រុកអណ្តូងមាស ខេត្តរតនគិរី។

- លោកបានចូលរួមជាមួយជាមួយបដិវត្តន៍ខ្មែរក្រហមដំបូងក្នុងតួនាទីជានីរសារ។ មនុស្សម្នាក់ក្នុងចំណោមមនុស្សទាំងប៉ុន្មានដែលលោកបានយកលិខិតទៅជូន មានឈ្មោះ វ៉ាន់ ជាគណៈកម្មាធិការភូមិភាគឦសាន។ លោកមិនស្គាល់ឈ្មោះផ្សេងទៀតរបស់ វ៉ាន់ ទេ។
- បន្ទាប់មក លោក រម៉ាម យុន ត្រូវបានតែងតាំងជាប្រធានភូមិ ហើយក្រោយមកជាប្រធានឃុំ និងប្រធានស្រុក ជាបន្តបន្ទាប់។
- លោក រម៉ាម យុន ត្រូវបានគេអញ្ជើញទៅចូលរួមប្រជុំដែលពិភាក្សាអំពី កសិកម្ម បញ្ហាសុខភាព សីលធម៌បដិវត្តន៍ វិធីសាស្ត្រគ្រប់គ្រងមនុស្ស និងវិធីសាស្ត្រដោះស្រាយបញ្ហា។
- នៅពេលសួរសំណួរអំពីស្ថានភាពនៅក្នុងឃុំ គាត់បានឆ្លើយថា៖

*"ខ្លះចងកដែរអ៊ីចឹង។ វាស្គមស្គាញពេក។ អាហ្នឹងហើយអង្គការថ្នាក់លើ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក គណៈខេត្ត គេថា អ្ហ៎! មូលដ្ឋានស្រួលណាស់ ដឹកនាំប្រទេសស្រួលណាស់ អត់អីទេ! ស្រួលម៉េច! យើងនៅដល់ស្រុក ចុះក្រោមវាមិនស្រួលមិនម៉េច!។"*




*ទិដ្ឋភាពទូទៅនៃបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)* *(រូបថត: ម៉េង គីមឡុង)*

# សេចក្តីណែនាំសម្រាប់អ្នកចូលរួមស្តាប់សវនាការ

**កាលវិភាគសវនាការនាពេលខាងមុខ**

- ពីថ្ងៃទី១២ ខែមីនា ដល់ថ្ងៃទី២១ ខែមិថុនា ២០១២
- ថ្ងៃច័ន្ទ - ថ្ងៃព្រហស្បតិ៍ (លើកលែងថ្ងៃបុណ្យជាតិ)
- ម៉ោង ៩:០០ ព្រឹក ដល់ ៤:០០ រសៀល
- តាមធម្មតា អង្គជំនុំជម្រះនឹងសួរដេញដោលជនជាប់ចោទនៅក្នុងសវនាការពេលព្រឹក និង សួរសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលរសៀល។

**នៅក្នុងសាលសវនាការ**

អ្នកចូលរួមត្រូវតែមានសម្លៀកបំពាក់សមរម្យ និងរក្សាសេចក្តីថ្លៃថ្នូរនិងរបៀបរៀបរយ។ មិនអនុញ្ញាតឲ្យស្លៀកខោខ្លី សម្លៀកបំពាក់នៅមាត់សមុទ្រ ឬសម្លៀកបំពាក់ស្តើងហួសហេតុ ឬពាក់ស្បែកជើងផ្ទាត់។ល។ ***អ្នកចូលរួមមិនត្រូវស្លៀកសម្លៀកបំពាក់ដែលមានពាក្យស្លោកដែលបង្ហាញការគាំទ្រឬមាក់ងាយដល់ក្រុមណាមួយឡើយក្នុងអំឡុងសវនាការ***។ សូមកត់សម្គាល់ថា អ្នកដែលមានអាយុក្រោម ១៦ឆ្នាំ មិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងសាលសវនាការឡើយ ហើយអ្នកដែលមានអាយុចាប់ពី១៦-១៨ឆ្នាំ ត្រូវបានអនុញ្ញាតឲ្យចូលក្នុងសាលសវនាការតែក្នុងករណីមានមនុស្សចាស់មកជាមួយប៉ុណ្ណោះ។ មិនអនុញ្ញាតឲ្យយកទូរស័ព្ទដៃ កាបូបធំៗ ម្ហូបអាហារ ឬភេសជ្ជៈចូលក្នុងសាលសវនាការឡើយ។

អ្នកចូលរួមត្រូវបានសំណូមពរឲ្យអង្គុយនៅនឹងកន្លែងនិងរក្សាភាពស្ងៀមស្ងាត់ក្នុងអំឡុងពេលសវនាការ ប៉ុន្តែក្នុងករណីដែលត្រូវការប្រើបន្ទប់ទឹកជាចាំបាច់ អាចទៅបានដោយដើរតាមទិសដៅដែលចង្អុលបង្ហាញដោយមន្ត្រីសន្តិសុខ។ ***មានបន្ទប់ទឹកចំនួនពីរ មួយនៅជាន់ផ្ទាល់ដី និងមួយទៀតនៅជាន់ខ្ពស់តឿ***។ ក្នុងអំឡុងពេលសម្រាក អ្នកចូលរួមគួរតែយកសម្ភារៈផ្ទាល់ខ្លួនតាមជាប់ខ្លួនជានិច្ច។

**ភាសាដែលប្រើនៅក្នុងសវនាការ**

អ.វ.ត.ក ផ្តល់ការបកប្រែប្រដេញជាបីភាសា គឺភាសាខ្មែរ អង់គ្លេស និងបារាំង។ ការផ្សាយនៅក្នុងសាលសវនាការគឺជាភាសាខ្មែរ ហើយភាសាអង់គ្លេសនិងបារាំងអាចស្តាប់បានតាមរយៈកាសត្រចៀក ដោយចុចប៊ូតុងលេខ ២ សម្រាប់ភាសាអង់គ្លេស និងប៊ូតុងលេខ ៣ សម្រាប់ភាសាបារាំង។

**តើធ្វើយ៉ាងណាដើម្បីទៅដល់ អ.វ.ត.ក ?**

អ.វ.ត.ក ស្ថិតនៅខាងឆ្វេងដៃនៃផ្លូវជាតិលេខ៤ ក្នុងសង្កាត់ចោមចៅ ចម្ងាយ១៦គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ សាធារណជន និងអ្នកសារព័ត៌មានសូមចូលតាមច្រកទ្វារសម្រាប់ភ្ញៀវដែលស្ថិតនៅទិសខាងកើត។